## ៨-១-៨ បុណ្យជូនកុសលដល់ មនុស្សឈឺ ឬ មនុស្សស្លាប់

១-មនុស្សឈឺ

នៅប្រទេសខ្មែរយើង កាលណានៅក្នុងគ្រួសារ មាន មនុស្សចាស់ ឈឺ ដូចជាឪពុកម្តាយជាដើម កូនចៅច្រើននិយម ធ្វើបុណ្យដោយនិមន្តព្រះសង្ឃមកឯផ្ទះដើម្បី ប្រទានសីល ដល់អ្នកជម្ងឺ និង ទទួលចង្ហាន់ សង្ឃទាន ។

ជួនកាលគេធ្វើសង្ឃទានចំនួន៣ថ្ងៃ ឬ ៧ថ្ងៃជាប់គ្នា ទៅតាមធនធាន ដែលអាចធ្វើបាន។ ដោយបុណ្យកុសលជួយ អ្នកជម្ងឺខ្លះ ជាសះស្បើយក៏មាន បើមិនជាទេ ក៏យើងបានធ្វើបុណ្យជូនគាត់ ទាន់គាត់នៅរស់ដែរ ។

បើអ្នកជម្ងឺនៅមន្ទីរពេទ្យ គេអាចនិមន្តព្រះសង្ឃមកទទួលចង្ហាន់បានដែរ ស្រេចតែយើងទាក់ទងខាងមន្ទីរពេទ្យ។

បើអ្នកជម្ងឺនៅផ្ទះ គេមាននិមន្តព្រះបដ តាំងតាមជញ្ជាំង និង តាំងនៅតាមពីដានផ្ទះ ដើម្បីឲ្យអ្នកជម្ងឺឃើញព្រះពុទ្ធរូប ជាហេតុធ្វើឲ្យអារម្មណ៍គាត់ មូលនៅតែក្នុងកុសលម្យ៉ាង។ ពេលល្ងាចគេនិមន្តព្រះសង្ឃសូត្រធម៌ប្រែ រឿងគិរីមានន្ទ (រឿងសញ្ញា១០ប្រការ) ព្រោះកាលសម័យព្រះពុទ្ធ មានភិក្ខុ មួយអង្គព្រះនាម គិរីមានន្ទ លោកមានអាពាធ លុះព្រះអានន្ទ លោកសូត្រធម៌នេះទៅ ព្រះគិរីមានន្ទ លោកក៏បានជាសះស្បើយ ។

ក្រៅពីនេះ ព្រះសង្ឃ លោកសូត្រធម៌ ៖

អនិច្ចំ ទុក្ខំ អនត្តា ដូចជា អនត្តលក្ខណសូត្រ។ នៅក្នុង គម្ពីរមាន តំណាលថា សូត្រសតិប្បដ្ឋាន ក៏មាន សូត្រពោជ្ឈង្គ ក៏មាន ប៉ុន្តែ គ្រឹះធំ គឺ គិរីមានន្ទសូត្រ ។

បន្ទាប់ពីព្រះសង្ឃសូត្ររួចទៅ គេអាចអញ្ជើញចាស់ទុំនៅក្នុងភូមិ ឲ្យមកសូត្រ

ធម៌ និយាយអំពីគុណបារមី ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហៅធម៌ ការវតា(*) មិនមែនធម៌ អភិធម្ម ទេ ។

បើនៅមន្ទីរពេទ្យ គេពុំអាចធ្វើបានដូចនៅផ្ទះទេ ព្រោះខ្លាចរំខានដល់អ្នកជិតខាង តែជួនកាលគេអាចចាក់កាសែត្រ (ក៧) ធម៌គិរីមានន្ទសូត្រ ជូនគាត់ស្តាប់បានដែរ ដោយបើកសំឡេងតិចៗ។ បើអាចធ្វើបាន គេនាំគាត់ខមាទោស ព្រះរតនត្រ័យ ថ្វាយខ្លួនសាជាថ្មី គឺថា សម្រិតសម្រាំង អំពីសីល អំពីត្រៃសរណគមន៍ ឲ្យបានស្អាត ព្រោះថា ការស្លាប់មិនទៀង ។

ប៉ុន្តែយើងធ្វើមើលមនុស្សដែរ បើជាមនុស្សធ្លាប់ ប្រតិបត្តិធម៌ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងនោះ បើយើងធ្វើតាមរបៀបខាងលើនេះ គាត់នឹងសប្បាយចិត្ត តែបើគ្រាន់តែជាមនុស្សកាន់ព្រះពុទ្ធសាសនាតាមតែទំនៀមទម្លាប់ទេនោះ បើគាត់នៅដឹងមានសតិស្មារតីនៅឡើយ យើងគ្រាន់តែពន្យល់ធម៌គាត់ កុំឲ្យគាត់ជាប់ជំពាក់ចិត្តនឹងទ្រព្យសម្បត្តិ កូនចៅ ព្រោះដល់ពេលនេះហើយ គាត់ជួយអ្វីថែមទៀតលែងបានហើយ ត្រូវនឹកគិតតែ សេចក្តីល្អ អំពើល្អដែល ធ្លាប់បានធ្វើ នឹកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលលោកបានបង្ហាញផ្លូវ ដើរទៅរកសេចក្តីសុខ ស្ងប់អស់ តណ្ហា ឧបាទាន ។

ធ្វើបុណ្យជូនគាត់នៅពេលគាត់ដឹង មានស្មារតី នៅឡើយ នាំឲ្យចិត្តគាត់ ជ្រះថ្លាប្រសើរជាងពេលដែលគាត់លែងដឹងខ្លួន ។

---

(*) អាការវត្តា

២- លុះគាត់ស្លាប់ហើយ

ខាងព្រះពុទ្ធសាសនាមិនមានកិច្ចអ្វីប្រញាប់ប្រញាល់ពេក ក័យពេកនោះទេ ព្រោះគាត់ឈឺយើងក៏ដឹងជាមុនរួចទៅហើយ បើមិនបាននិមន្តលោកទៅសូត្រធម៌ភ្លាម នោះ ក៏អត់ខុសឆ្គងអ្វីដែរ ធ្វើតែទៅតាមសម្រួលហូរហែទៅ ។

កិច្ចដែលគួរធ្វើគឺ ៖

បើស្លាប់នៅមន្ទីរពេទ្យយើងនិមន្តព្រះសង្ឃទៅបង្សុកូល យ៉ាងតិចមួយដងទៅ មុនថ្ងៃបញ្ចុះ ឬ បូជាសព។ ជាមួយគ្នានោះនៅផ្ទះ បើយើងមានលទ្ធភាព យើងអាចនិមន្តព្រះសង្ឃធ្វើបុណ្យសង្ឃទានរាល់ៗថ្ងៃ ឬមួយនៅវត្ត យើងអាចចូលលុយនឹងយាយៗធ្វើចង្ហាន់លោករាល់ថ្ងៃ ដើម្បីឧទ្ទិសកុសលទៅដល់អ្នកដែលស្លាប់នោះក៏បាន ។

-លុះដល់ថ្ងៃគេអញ្ជើញសពចេញទៅបូជាឬបញ្ចុះ គេនិមន្តព្រះសង្ឃមកកន្លែងតម្កល់សព មុនពេលគេបិទក្តារមឈូស។ ព្រះសង្ឃលោកសូត្រធម៌បង្សុកូលរួចហើយក៏គង់ក្នុងរថយន្តដឹកសព ដង្ហែជាមួយនឹងកូន ឬចៅម្នាក់កាន់រូបថតសព។

៣- នៅឈាបនដ្ឋាន

លុះគេយកក្តារមឈូសសពមកដល់ហើយ ត្រូវរៀបចំកន្លែងតម្កល់ព្រះពុទ្ធរូប ដោយមាន ជើងទៀនសម្រាប់ទ្រទៀនមួយគូ និង ប្រដាប់សំរាប់ដោតធូប២ (មួយនៅមុខព្រះពុទ្ធរូប មួយទៀតនៅមុខក្តារមឈូសសព) ។

ការចាប់ផ្តើមពិធីមានគោលៗដូចតទៅនេះ ៖

១-ថ្វាយបង្គំព្រះ

២ -សមាទាននិច្ចសីល

៣-សុន្ទរកថា អំពីជីវប្រវត្តិ សព

៤-ការថ្វេងអំណរគុណពីកូនចៅដល់ភ្ញៀវ(បើខ្វះពេលត្រូវធ្វើនៅពេលជាបន្ទាប់ក៏បាន)

៥-ព្រះសង្ឃសូត្រធម៌

៦-អញ្ជើញភ្ញៀវដាក់ផ្កា

៧-គេលើកសព យកទៅបូជា

៨-សុន្ទរកថា របស់ភ្ញៀវ ឬ មិត្តភក្តិ (បើមាន)

៩-កូនចៅថ្វេងអំណរគុណដល់ភ្ញៀវ (បើពុំទាន់ធ្វើ)

១០-និមន្តព្រះសង្ឃសម្តែងធម្មទេសនាមុខភ្លើង (បើមាន)

១១-ចប់ពិធី ព្រះសង្ឃនិងភ្ញៀវត្រឡប់ទៅផ្ទះ ។

១២-កូនចៅនៅចាំទទួលធាតុ ។

<u>សង្កេត</u>

ឱកាសអញ្ជើញសពទៅបូជា បើចង់បានធ្អឹងធំៗខ្វះត្រូវប្រាប់ទៅបុគ្គលិកធ្វើការបូជាជាមុន ។

<u>៤- ដល់គ្រប់ ៧ថ្ងៃ ១០០ថ្ងៃ ឬ ខួបប្រចាំឆ្នាំ</u>

គេអាចធ្វើបុណ្យនៅវត្តក៏បាន នៅផ្ទះក៏បានឬមួយយកម្ហូបមកវត្តតែមួយស្រាក់ក៏បានដែរ មិនមានអ្វីជាកំណត់ទេ។

នៅស្រុកបារាំងបើគេធ្វើបុណ្យ គេច្រើនរើសយកថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ទោះថ្ងៃនោះមិនចំថ្ងៃខួបក៏ដោយ ក៏មិនអីដែរ នេះដើម្បីឲ្យមិត្តភក្តិ បងប្អូនដែលជាប់ការងារមាន ឱកាសមកចូលរួមផង ។

អ្នកខ្លះគេធ្វើបុណ្យ៧ថ្ងៃនៅផ្ទះ លុះដល់បុណ្យ១០០ថ្ងៃទើបគេធ្វើនៅវត្ត ដោយជំរាប
មិត្តភក្តិថា បុណ្យ ១០០ ថ្ងៃ។

គម្ពីរព្រះពុទ្ធសាសនា ប្រៀនប្រដៅឲ្យកូនចៅ ចេះដឹងគុណគាត់ ថែទាំគាត់ឲ្យល្អ កាល
គាត់នៅរស់ លុះគាត់ស្លាប់ហើយ គេត្រូវធ្វើបុណ្យឧទ្ទិសកុសលជូនគាត់ទៀត តាម
សមគួរ ឥតមានកំណត់ពេលវេលា ឬ ពិធីបុណ្យទេ។ តាមទំនៀមទម្លាប់កាលណាគាត់
ស្លាប់បានមួយឆ្នាំហើយ កូនចៅគេធ្វើបុណ្យខួប របៀបធ្វើបុណ្យ គេធ្វើធំក៏បាន តូចក៏
បាន ដូចជំរាបមកខាងលើរួចហើយ ។ ចាប់តាំងពីមួយឆ្នាំឡើងទៅ គេធ្វើបុណ្យខួបនេះ
រាល់ៗឆ្នាំ ៕

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។